# ប្រយ័ត្នចំពោះ
# .exe, .zip ឬ .rar
# ដែលទទួលបានពី Telegram



ថ្មីៗនេះអ្នកប្រើប្រាស់ Telegram ជាច្រើន ទទួលសារដែលមានភ្ជាប់មកជាមួយនូវឯកសារមិនស្គាល់ប្រភពច្បាស់លាស់ពីមិត្តភ័ក្តិ ក្រុមតេលេក្រាម និងពីឆានែលផ្សេងៗ។ ឯកសារទាំងនោះភាគច្រើនមានឈ្មោះមិនច្បាស់លាស់ និងបញ្ចប់ដោយ .exe .zip, .rar ឬ .apk ជាដើម។




ករណីនេះអាចបណ្តាលមកពី មានជនខិលខូចលួចនៅក្រុម telegram នោះ ឬគណនីតេលេក្រាមអ្នកដែលផ្ញើមក មិនបានយល់ដឹង ឬគណនីពួកគេត្រូវបានជនខិលខូចលួចចូលប្រើ និងគ្រប់គ្រង ។ល។

អង្គការអនាគតឌីជីថលកម្ពុជា
Digital Future Cambodia Organization

DigitalHub101

# មានបញ្ហាអ្វី បើអ្នកចុចលើឯកសារទាំងនោះ?

នៅពេលអ្នកចុច មានន័យថាអ្នកបានទាញយកឯកសារទាំងនោះ និងបានរក្សាទុកក្នុងទូរស័ព្ទ ឬកុំព្យូទ័រអ្នករួចហើយ។

ការទាញយកឯកសារពីតេលេក្រាម មិនមែនមានន័យថាឧបករណ៍របស់អ្នកនឹងឆ្លងមេរោគភ្លាមៗនោះទេ។ ប៉ុន្តែវាជាជំហានដំបូង ដែលអាចឱ្យអ្នកបើក ឬដំឡើងមេរោគចូលទៅក្នុងឧបករណ៍អ្នក ដោយមិនដឹងខ្លួន។

អង្គការអនាគតឌីជីថលកម្ពុជា
Digital Future Cambodia Organization

DigitalHub101

# តើប្រភេទឯកសារទាំងនេះ មានន័យដូចម្ដេច?

- .exe ជាកម្មវិធីសម្រាប់ដំឡើងលើកុំព្យូទ័រ Windows
- .apk ជាប្រភេទកម្មវិធី សម្រាប់ដំឡើងលើទូរស័ព្ទ android
- .rar និង .zip គឺជាឯកសារអាចផ្ទុកឯកសារជាច្រើនទៀតនៅក្នុងនោះ

ឧក្រិដ្ឋជនអាចប្រើឯកសារ .exe, .apk សម្រាប់ឡើងមេរោគផ្ទាល់ចូល កុំព្យូទ័រ ឬទូរស័ព្ទអ្នក និងតែងប្រើឯកសារ ប្រភេទ .rar ឬ .zip ដើម្បីលាក់មេរោគ។

អង្គការអនាគតឌីជីថលកម្ពុជា
Digital Future Cambodia Organization

DigitalHub101

# តើមេរោគទាំងនោះអាចធ្វើអ្វីបានខ្លះ?

- លួចពាក្យសម្ងាត់ និងលួចគណនី telegram, facebook និងគណនីអនឡាញផ្សេងទៀតរបស់អ្នក
- លួចចម្លងឯកសារ រូបថត និងបញ្ជីទំនាក់ទំនង
- តាមដានសកម្មភាពនៃការប្រើឧបករណ៍ និងអ៊ីនធឺណិតរបស់អ្នក
- អានសារ ឬការជូនដំណឹង
- គ្រប់គ្រងឧបករណ៍របស់អ្នកពីចម្ងាយ
- ដំឡើងមេរោគបន្ថែមចូលក្នុងឧបករណ៍អ្នក
- ប្រើគណនីរបស់អ្នក ដើម្បីឆបោក ឬវាយប្រហារអ្នកដទៃ

# ចំណុចគួរចងចាំ

ត្រូវពិនិត្យ ផ្ទៀងផ្ទាត់មុននឹងចុច។
កុំបើក និងកុំដំឡើងឯកសារមិនស្គាល់
ប្រភពច្បាស់លាស់។



អង្គការអនាគតឌីជីថលកម្ពុជា
Digital Future Cambodia Organization

DigitalHub101